# សុន្ទរកថា
# លោកស្រី អ៊ុង ច័ន្ទថុល នាយិកាប្រតិបត្តិ អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ
# ក្នុងពិធីសម្ពោធមណ្ឌលសុវត្ថិភាព និងរបាយការណ៍សកម្មភាពការងារ
# និងសមិទ្ធផលរយៈពេល១០ឆ្នាំ នៃអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ
# ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៦
# នៅមណ្ឌលសុវត្ថិភាព ខេត្តបន្ទាយមានជ័យ

- ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំព្រះថេរានុថេរៈគ្រប់ព្រះអង្គ ជាទីគោរពសក្ការៈ
- សូមគោរពឯកឧត្តម អន ស៊ី តំណាង អភិបាលខេត្តបន្ទាយមានជ័យ តំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃជាទីគោរព
- សូមគោរព លោកជំទាវ យូ អយ រដ្ឋលេខាធិការ ក្រសួងកិច្ចការនារី ជាទីគោរព
- សូមគោរពឯកឧត្តម អភិបាលខេត្តរង ខេត្តបន្ទាយមានជ័យ ជាទីគោរព
- សូមគោរព លោក ទូ វ៉ាន់ថា ប្រធានសំរបសំរួលនៃអង្គការមូលនីធិ TDH អាល្លឺម៉ង់ និងតំណាងអង្គការមូលនីធិដទៃ ៗទៀត ទីមេត្រី!
- សូមគោរពឯកឧត្តម លោកជំទាវ អគ្គរាជទូត អគ្គរដ្ឋទូត និងអង្គទូតទាំងអស់ជាទីគោរព!
- សូមគោរពលោកស្រី ប្រធានក្រុមប្រឹក្សាភិបាលនៃអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិជាទីកោរព
- សូមគោរព បុគ្គលិក បណ្ឌាញ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្សភ្ញៀវជាតិ និងភ្ញៀវអន្តរជាតិជាទីគោរព និងជាទីរាប់អាន!

ជាបឋម តាងនាមអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ ខ្ញុំព្រះករុណា នាងខ្ញុំសូមគោរពថ្លែងអំណរព្រះគុណ និងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះវត្តមានដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម តំណាងឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង មហាផ្ទៃ ព្រះថេរានុថេរៈគ្រប់ព្រះអង្គ ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត អគ្គរដ្ឋទូត លោក លោកស្រីទាំងអស់ ដែលបានឆ្លៀតពេលវេលាដ៏មមាញឹកអញ្ជើញមកចូលរួមជាអធិបតីដ៏ខ្ពង់ខ្ពស់នៅក្នុងពិធីសម្ពោធមណ្ឌលសុវត្ថិភាពបណ្ឌិតវ៉ល ធី និងទិវាខួប ១០ឆ្នាំនៃអង្គការកម្ពុជាដើម្បីជួយស្រីមានវិបត្តិ ដ៏មហោឡារឹក និងអធឹកអធមនេះ ។

ខ្ញុំព្រះករុណា នាងខ្ញុំសូមអនុញ្ញាតិទូលប្រគេនព្រះថេរានុថេរៈគ្រប់ព្រះអង្គ និងជំរាបជូនឯកឧត្តម លោកជំទាវ លោក លោកស្រី គណៈអធិបតី ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់មេត្តាជ្រាបថា ពិធីថ្ងៃនេះត្រូវបានរៀបចំឡើងក្នុងគោលបំណងធំ២ពីរៈ

ទី១- សំដែងនូវការដឹងគុណចំពោះលោកបណ្ឌិតវ៉លធី

ទី២-រំលឹកខួប១០ឆ្នាំ និងចែកចាយពីបទពិសោធន៍ និងសមិទ្ធិផលនៃអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ

ខ្ញុំព្រះករុណា នាងខ្ញុំសូមអនុញ្ញាត ទូល និងជំរាបគណៈអធិបតី និងអង្គពិធីទាំងមូល អំពីដំណើរការកសាង និងអត្ថប្រយោជន៏នៃមណ្ឌលសុវត្ថិភាពខេត្តបន្ទាយមានជ័យ ដែលនឹងធ្វើពិធីសម្ពោធជាផ្លូវការនៅក្នុងថ្ងៃនេះ ។ មណ្ឌលសុវត្ថិភាព បណ្ឌិត រ៉ៃលធី ត្រូវបានកសាងឡើងក្រោមជំនួយមនុស្សធម៌របស់អង្គការម្ចាស់មូនីធិរួមមាន TDH-G, TDH-N, BMZ, UNICEF, OXFAM-H.K និង DCA ដែលបានបរិច្ចាគថវិកាដ៏ថ្លៃថ្លា សរុបចំនួនប្រមាណជា ដប់ពីរម៉ឺនដុល្លារសហរដ្ឋអាមេរិក (១២0,000USD) ក្នុងការជួយកសាង និងធ្វើអោយមណ្ឌលនេះកើតចេញជារូបរាងឡើងយ៉ាងពិតប្រាកដ ។ មណ្ឌលសុវត្ថិភាពខេត្តបន្ទាយមានជ័យ រួមមានបួនអគារៈ

- អគារធំមួយខ្នង កំពស់មួយជាន់ ទំហំ ៤0 ម៉ែត្រគុណនឹង ១0 ម៉ែត្រ មាន ៦បន្ទប់ ជាអគារសំរាប់ហ្វឹកហ្វឺនវិជ្ជាជីវៈរួមមាន កាត់ដេរ តំបាញសូត្រ សំអាងកាយ និងសំអាងការ តំបាញកន្ទេល សិប្បកម្មផលិតវត្ថុអនុស្សាវរីយ៏ វិជ្ជាធ្វើម្ហូប បោះពុម្ព ថ្នាក់អក្ខរកម្ម និងមតេយ្យសាលា ជូនដល់ស្ត្រី និងកុមាររងគ្រោះ និងងាយរងគ្រោះដោយអំពើហិង្សាគ្រប់ប្រភេទ មានដូចជា អំពើហិង្សាក្នុងគ្រួសារ ការជួញដូរមនុស្ស ការរំលោភសេពសន្ថវៈ ។ល។

- អគារបីខ្នងទៀត ក្នុងមួយខ្នងមានទំហំ ១0 ម៉ែត្រ គុណនឹង ១0 ម៉ែត្រ មានកំពស់ពីរជាន់ ជាទីកន្លែងសំរាប់ស្នាក់នៅបណ្តោះអាសន្នរបស់ស្ត្រី និងកុមារ ជាជនរងគ្រោះ និងងាយរងគ្រោះ ដោយអំពើហិង្សាគ្រប់ប្រភេទខាងលើ ។

អគារទាំងអស់នៃមណ្ឌលសុវត្ថិភាពខេត្តបន្ទាយមានជ័យនេះបានសាងសង់រួចរាល់ នៅពាក់កណ្តាលឆ្នាំ ២00៦ នេះ និងអាចទទួលស្រី និងកុមារអោយស្នាក់នៅបាន ចំនួនប្រមាណជា ១៦0នាក់ ។

មណ្ឌលសុវត្ថិភាពត្រូវបានបំពាក់នូវឧបករណ៏សំភារៈមានដូចជាៈ គ្រែឈើចំនួន២៨- គ្រែដែកពីរជាន់មានពូកចំនួន២៥ កង្ហារ ៥0-កេសដែកសំរាប់ដាក់សំលៀកបំពាក់៦0- កីតំបាញសូត្រចំនួន៥- កីតំបាញកន្ទេលចំនួន៥- ម៉ាស៊ីនដេរចំនួន ៥0- ម៉ាស៊ីនផុង ចំនួន៤- តុបាយចំនួន៦0- កៅអីជ័រ ១២0- កៅអីសំរាប់សិស្សមតេយ្យ៣0- ក្តារខៀន- តុឈើសំរាប់ថ្នាក់អក្ខរ កម្ម ចំនួន៣0- ឧបករណ៏ក្មេងលេង និងសៀវភៅនិទានរឿងខ្លីៗ សៀវភៅគំនូរ សៀវភៅសំរាប់ថ្នាក់អក្ខរកម្មថ្នាក់ ទាប មធ្យម និងខ្ពស់ ជាច្រើនទៀត ។ ដោយឡែក អ្នកស្នាក់ក្នុងមណ្ឌលសុវត្ថិភាពទាំងបី ត្រូវបានទទួលនូវសេវា ពិគ្រោះយោបល់ ពិគ្រោះផ្លូវចិត្ត ការថែទាំសុខភាព ការការពារផ្នែកផ្លូវច្បាប់ ការផ្តល់មេធាវី អាហារ សំលៀកបំពាក់ និងវិជ្ជាជីវៈជំនាញ ។

ព្រះថេរានុថេរៈគ្រប់ព្រះអង្គជាទីគោរពសក្ការៈ!

ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអ្នកនាងកញ្ញា ជាទីគោរព និងជាទីសឡាញ់រាប់អាន !

ខ្ញុំព្រះករុណា នាងខ្ញុំសូមទូល និងជំរាបជូនគណៈអធិបតី ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ និងភ្ញៀវអន្តរជាតិ ពីប្រវត្តិសកម្មភាព សមិទ្ធិផល ដែលអង្គការ CWCC ទទួលបាន និងបញ្ហាប្រឈមមុខក្នុងកំលុងពេលដប់ឆ្នាំកន្លងមកនេះ

អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ ត្រូវបានបង្កើតឡើងដោយស្ត្រីមួយក្រុមនៅទីក្រុងភ្នំពេញ នៅចុងឆ្នាំ ១៩៩៤ ហើយបានចុះឈ្មោះជាផ្លូវការ នៅខែមីនា ឆ្នាំ ១៩៩៧។ ទស្សនៈវិស័យ គឺលុបបំបាត់អំពើហិង្សាលើស្ត្រី និងកុមារ ដើម្បីសំរេចអោយបាននូវសមភាព សន្តិភាព អភិវឌ្ឍន៍ និងសុភមង្គលក្នុងក្រុមគ្រួសារ និងសង្គមជាតិ។ អង្គការនេះត្រូវបានបង្កើតឡើងដោយសារតែមានស្ត្រីជាច្រើនត្រូវបានគេជួញដូរហើយ ស្រីជាច្រើនត្រូវបានប្តីវាយដំ និងមានស្ត្រីជាច្រើនទៀតត្រូវបានគេរំលោភសេពសន្ថវៈ ហើយពេលនោះពុំទាន់មានសេវាកម្មជួយសង្គ្រោះអោយ ប ានគ្រប់គ្រាន់នៅឡើយ។ ជាក់ស្តែង ក្នុងកំលុងពេលនៃការស្រាវជ្រាវក្នុងឆ្នាំ១៩៩៤ ក្រុមស្រាវជ្រាវពីអង្គការស្ត្រីចំនួន ១៦ បានជួបកុមារីរងគ្រោះដោយការជួញដូរ ៥នាក់ដែលត្រូវគេវាយធ្វើបាបឈាមពេញខ្លួន រត់អោយគេជួយប៉ុន្តែ មិនមាននរណាម្នាក់ហ៊ានជួយឡើយ ដោយសារមានក្រុមជើងកាងផ្ទះបនដេញតាមចាប់ពីក្រោយ ហើយជនរងគ្រោះបានរត់មករកអង្គការសិទ្ធិមនុស្សអោយជួយ ។ ជាអកុសលពេលនោះ ពុំទាន់អង្គការណាមានសេវាកម្មជួយសង្គ្រោះជនរងគ្រោះនៅឡើយ ។ ករណីផ្សេងមួយទៀតមានស្រីមានផ្ទៃពោះម្នាក់ដែលត្រូវប្តីវាយធ្វើបាប បានរត់ទៅសុំអ្នកជិតខាងស្នាក់នៅមួយយប់ ដើម្បីអោយប្តីបាត់ខឹងទើបត្រលប់ទៅផ្ទះវិញ ប៉ុន្តែសំណើនេះត្រូវបាន បដិសេធដោយកីអាណិតអាសូរ ព្រោះខ្លាចប្តីស្ត្រីនោះមករករឿង និងចាត់ទុកថារឿងហិង្សាក្នុងគ្រួសារគឺជារឿង បុគ្គល ។ ទីបញ្ចប់ស្រីនោះបានត្រលប់មកផ្ទះវិញ ហើយត្រូវប្តីចងផ្អោបជាមួកូនពីរនាក់ផ្សេងទៀត ហើយចាក់នឹងកាំបិតជាច្រើនកន្លែង រួចហើយចាក់សាំងដុតសំលាប់តែម្តង ។ ក្នុងពេលនោះក៏មានស្ត្រីជាច្រើនត្រូវបានគេរំលោភ និងសំលាប់ ហើយជារឿយ ៗ ជនរងគ្រោះត្រូវបានគេបន្ទោសថាមកពីស្រីនោះដើរ រឺនៅតែម្នាក់ឯង រឺស្លៀកពាក់មិនសមរម្យដែលធ្វើអោយគេទ្រាំមិនបាន ។ មូលហេតុទាំងអស់នោះហើយដែលនាំអោយក្រុមស្រីយើងផ្តួចផ្តើមគំនិតបង្កើតជាអង្គការកម្ពុជាដើម្ពីជួយស្រីមានវិបត្តិឡើង ដែលជាដំបូងគ្រាន់តែបង្កើតមណ្ឌលសុវត្ថិភាពសំរាប់អោយជនរងគ្រោះស្នាក់នៅពីរ រឺបីយប់ដើម្បីការពារ សុវត្ថិភាពបណ្តោះ អាសន្នមុនពេលត្រលប់ទៅផ្ទះវិញ ។

អង្គការកម្ពុជាដើម្បីជួយស្រីមានវិបត្តិមានបុគ្គលិកចំនួន ៤នាក់នៅពេលចាប់ផ្តើមដំបូង និងមានទីស្នាក់តែមួយនៅទីក្រុងភ្នំពេញ ។ រំលងតែមួយសប្តាហ៍ប៉ុណ្ណោះ មណ្ឌលយើងទទួលបានក្មេងស្រីដែលរងគ្រោះដោយសារការជួញដូរចំនួន៣០នាក់ ហើយស្ត្រីទាំងនោះត្រូវការត្រលប់ទៅផ្ទះវិញ ប៉ុន្តែទាំងស្ត្រី និងអង្គការយើងមិនទាន់មានថវិកាក្នុងការបញ្ជូនពួកគាត់ត្រលប់ទៅផ្ទះវិញ ។ ទោះជាយ៉ាងនោះក៏ដោយ យើងបានផ្ញើពួកគាត់តាមឡានរបស់អង្គការផ្សេង១ទៀតដែលត្រូវធ្វើដំណើរទៅខេត្តពួកគាត់រៀង១ខ្លួន ។ ក្រោយពេលនោះ យើងបានរៃអង្គាសថវិកាដើម្បីចាប់ផ្តើមកម្មវិធីសមាហរណកម្មបន្ថែមទៀត ។ ក្នុងឆ្នាំទីមួយនេះ មណ្ឌលរបស់អង្គការមានស្ត្រីរងគ្រោះស្នាក់នៅដ៏ច្រើនលើសចំណុះដែលយើងមិនអាចទទួលបន្ថែមទៀតបាន ។ ដូចនេះ យើងសំរេចចិត្តបង្កើតកម្មវិធីផ្សព្វផ្សាយតាមទូរទស្សន៍អំពីល្បិចកលបោកបញ្ឆោត ដើម្បីអោយស្ត្រី និងគ្រួសារចេះការពារខ្លួនឯងពីការជួញដូរ ។ ដូច្នេះកម្មវិធីទាំងអស់របស់អង្គការត្រូវបានបង្កើតបន្ថែមដោយយោងទៅលើស្ថានភាពជាក់ស្តែង និងសេចក្តីត្រូវការរបស់ស្ត្រី ។ បច្ចុប្បន្ននេះ អង្គការបានពង្រីកទីស្នាក់ការការងារខ្លួននៅខេត្តបន្ទាយមានជ័យក្នុងឆ្នាំ ១៩៩៩

និងខេត្តសៀមរាបក្នុងឆ្នាំ ២០០១ ដោយមានបុគ្គលិកសរុបទាំងអស់ចំនួន ៨៩នាក់ និងអ្នកស្ម័គ្រចិត្តជាតិ និងអន្តរជាតិចំនួន ៧០០ នាក់ ។ បេសកកម្ម របស់អង្គការ គឺជួយស្ត្រីនិងកុមារអោយចាកផុតពីអំពើហិង្សាក្នុងគ្រួសារ ការជួញដូរ និងការរំលោភសេពសន្ថវៈ ជាពិសេស គឺអោយពួកគេអាចធ្វើការសំរេចចិត្ត និងចេះជួយខ្លួនឯង បាន តាមរយៈកម្មវិធី ទទួលពាក្យបណ្តឹង និងសង្គ្រោះ ផ្តល់ជំរកបណ្តោះអាសន្ន ផ្តល់ប្រឹក្សាយោបល់ផ្លូវចិត្ត និងច្បាប់ ផ្តល់មេធាវី ការធ្វើសមាហរណកម្ម ការចងក្រងសហគមន៍ ផ្តល់អាហារូបករណ៍ និងការតស៊ូមតិ អោយមានការគោរពសិទ្ធិ និងសុខមាលភាពរបស់ស្ត្រី និងកុមារ ។

**១-កម្មវិធីស៊ើបអង្កេតៈ** ទទួលពាក្យបណ្តឹង ប្រមូលព័ត៌មានដាក់ជូននគរបាលដើម្បីធ្វើអន្តរាគមន៍ជួយសង្គ្រោះស្ត្រីដែលរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារ ការរំលោភ ការជួញដូរយកទៅលក់ ទាំងនៅក្នុងប្រទេស និងទាំងនៅក្រៅប្រទេស (មានប្រទេស ម៉ាឡេស៊ី តៃវ៉ាន់ និង ប្រទេសថៃ) ។ ក្នុងរយៈពេល ១០ឆ្នាំកន្លងមកនេះ យើងទទួលបានជនរងគ្រោះសរុបទាំងអស់ប្រមាណជា ៩៧៣២ នាក់ ហើយបានសហការជាមួយនឹងនគរបាលសង្គ្រោះបានជនរងគ្រោះចំនួន ១៨០២ នាក់។

**២- មណ្ឌលសុវត្ថិភាពៈ** មណ្ឌលសុវត្ថិភាពទាំងបីនៃអង្គការបានទទួលស្ត្រី និងកុមាររងគ្រោះ ដែលគិតជាមធ្យម បានចំនួនប្រមាណជា ៤៧៦០នាក់ ។ អ្នករងគ្រោះប្រមាណជា ៦៩៧៤នាក់ដែលបានទទួលសេវាកម្មដោយផ្ទាល់ ដែលក្នុងនោះរួមមានស្ត្រី និងកុមារប្រមាណជា១៥១៤នាក់បានទទួលការបណ្តុះបណ្តាលផ្នែកអក្ខរកម្ម និងបញ្ចូលទៅក្នុងសាលារដ្ឋ ៦៧៦នាក់បានទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈនានា ដូចជា កាត់ដេរ ដាំស្ល តំបាញ ក្រម៉ា កន្ទេល រោងពុម្ព កាត់សក់ និងសំអាងការ ។ល។ ៤០៧២នាក់បានទទួលនូវសេវាកម្មពិគ្រោះយោបល់ផ្លូវ ច្បាប់ និងផ្លូវចិត្ត និង ៧១២នាក់បានទទួលនូវសេវាថែទាំសុខភាព ។

**៣-ការគាំទ្រផ្នែកច្បាប់ៈ** ជួយរៀបចំពាក្យបណ្តឹង និងផ្តល់មេធាវីការពារក្តីដល់ជនរងគ្រោះ ដោយអំពើហិង្សាគ្រប់ប្រភេទបានចំនួន ២៥០៩ករណី និងទទួលបានការឈ្នះក្តីរួមទាំងសំណងផ្លូវចិត្តដល់ជនរងគ្រោះបានចំនួនប្រមាណជា ៧០ ទៅ ៨០ ភាគរយថែមទៀតផង ។

**៤-សមាហរណកម្មៈ** អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ បានធ្វើសមារណកម្មស្ត្រី និងកុមាររងគ្រោះបានចំនួនប្រមាណជា ២៤៥៦នាក់ ដែលក្នុងនោះស្ត្រី និងកុមារចំនួន ២៨២នាក់ ដែលវិលទៅកាន់សហគមន៍វិញដោយមានការងារធ្វើ ហើយស្ត្រីនិងកុមារចំនួន ៥៨៣នាក់ ត្រូវបានបញ្ជូនទៅកាន់ក្រសួង ឬអង្គការមិនមែនរដ្ឋាភិបាលនានា និងចំនួន ១៥៩១នាក់ បានវិលត្រលប់ទៅកាន់គ្រួសារ និងសហគមន៍វិញដោយសុវត្ថិភាព ។ អង្គការ CWCC បានជួយឧបត្ថម្ភគាំទ្រ ទាំងផ្នែកស្មារតី និងទាំងថវិកា ជូនដល់ស្ត្រី និងកុមារ ដើម្បីអោយពួកគេអាចធានាបាននូវសុវត្ថិភាពក្នុងការរស់នៅ និងអាចប្រកបរបរចិញ្ចឹមជីវិតបានដោយខ្លួនឯង នៅពេលដែលពួកគេបានធ្វើសមាហរណកម្មទៅក្នុងសហគមន៍វិញ ។ ទន្ទឹមនឹងនេះ បុគ្គលិកអង្គការបានធ្វើការចុះសួរសុខទុក្ខពីការងារ ឬការប្រកបរបររកស៊ី

របស់ស្ត្រី និងកុមារទាំងនោះជារៀងរាល់បីខែ និងដោយមន្ត្រីសង្គមកិច្ចជារៀងរាល់ខែ ដើម្បីធានាថាពួកគេរស់នៅក្នុងសហគមន៍ និងគ្រួសារដោយសុវត្ថិភាព គ្មានការរើសអើង និងសុខស្រួល ។ ប៉ុន្តែទោះបីជាយ៉ាងនោះក៏ដោយ ក៏មានស្ត្រីប្រមាណជា ៤ភាគរយបានវិលត្រលប់ទៅប្រកបរបរពេស្យាចារវិញ រឺទទួលរងអំពើហិង្សាសារជាថ្មីឡើងវិញ ។

**៥- ការចងក្រងអប់រំសហគមន៍:** កម្មវិធីនេះមានគោលបំណងធ្វើអោយសហគមន៍ចូលរួមបំបាត់អំពើហិង្សាលើស្ត្រីដោយបានពង្រឹងសមត្ថភាពសហគមន៍ដូចតទៅ:

- បើកវគ្គបណ្តុះបណ្តាលចំនួន ៧៥៣ វគ្គ ដែលមានអ្នកចូលរួមសរុបចំនួន ១៥៤៩៥ នាក់ ដែលក្នុងនោះមាននគរបាលចំនួន ៣៩៧៩ នាក់ អាជ្ញាធរ ២១៧៣ នាក់ និងប្រជាពលរដ្ឋ និងអ្នកធ្វើការផ្នែកទេសចរណ៍ គ្រូបង្រៀន ចំនួន ៩៣៤៦នាក់ ។
- បើកវគ្គបណ្តុះបណ្តាលបណ្តាញចំនួន ៤២ វគ្គ មានអ្នកចូលរួមចំនួន ៩៤០ នាក់
- បើកវគ្គបណ្តុះបណ្តាលគ្រូបង្គោល ចំនួន ១វគ្គ មានអ្នកចូលរួមចំនួន ២១ នាក់
- កិច្ចសហការបណ្តុះបណ្តាលជាមួយដៃគូ CCJAP, TDH បានចំនួន ៩វគ្គ មានអ្នកចូលរួមជានគរបាលចំនួន ២៥៧នាក់
- ផលិតឯកសារផ្សព្វផ្សាយចំនួន ៤៧៥៤៨ ច្បាប់ ផ្ទាំងរូបភាពចំនួន ៤៦៥០០ ផ្ទាំង និងសៀវភៅរឿងអប់រំ ដូចជា អន្ទាក់ផ្លូវភេទ ខ្ញុំត្រូវតែចាកចេញ តើខ្ញុំគួរតែប្រាប់គេដែរឺទេ? តើការងារល្អនៅឯណា? មិនគួរទុកអោយការរងគ្រោះរបស់ខ្ញុំគ្មានន័យ ស្ពានជីវិត ច្បាប់និងសំណួរចំលើយទាក់ទងនឹងការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ការសិក្សាពីបទពិសោធន៍ល្អៗ គោលការណ៍ណែនាំក្នុងការជួយដល់ជនរងគ្រោះជួញដូរទាក់ទងនឹងអំពើហិង្សា ដែលក្នុងមួយរឿងៗត្រូវបានបោះពុម្ពជាច្រើនម៉ឺនច្បាប់ និងត្រូវអង្គការដទៃសុំសិទ្ធិបោះពុម្ពបន្ថែមរាប់ម៉ឺនច្បាប់បន្ថែមទៀត ។

**៦-បណ្តាញស្ម័គ្រចិត្ត:** បណ្តាញស្ម័គ្រចិត្តសរុបចំនួនប្រមាណជា ៩៤០នាក់ ដែលមានតួនាទីតាមដានពី សកម្មភាពនៃអំពើហិង្សា ការរំលោភសិទ្ធិស្ត្រីក្នុងសហគមន៍ ជួយសង្គ្រោះជនរងគ្រោះដោយអំពើហិង្សា គ្រប់ប្រភេទ ធ្វើការអប់រំ និងបញ្ជូនបន្តទៅរកសេវាកម្មនានា ។ ជាក់ស្តែងបណ្តាញផ្សព្វផ្សាយបន្តតាម សហគមន៍មានចំនួន ៥២២៤វគ្គ មានអ្នកចូលរួមចំនួន ១០៦៧៩៧ នាក់ និងបណ្តាញធ្វើអន្តរាគមន៍ជួយជនរងគ្រោះក្នុងសហគមន៍ បានចំនួន ៥៨២៤ករណី និងបានបញ្ជូនមកអង្គការ CWCC ចំនួន ១៦៨៩ នាក់

**៧-អាហារូបករណ៍:** កម្មវិធីនេះមានគោលបំណងទប់ស្កាត់ការជួញដូរកុមារ ដោយទប់ស្កាត់ការបោះបង់ការសិក្សារបស់កុមារ តាមរយៈការផ្តល់អាហារូបករណ៍ដល់កុមារីក្រីក្រចំនួន ៧៨៧ នាក់ ។ ការជួយរួមមាន ឯកសណ្ឋាន សំលៀកបំពាក់ សំភារៈសិក្សា អាហារ អង្ករ ខ្លាញ់ ត្រីខកំប៉ុង កន្លែងស្នាក់នៅ និងកង់ សំរាប់កុមារ ដែលមានទីលំនៅឆ្ងាយខ្លាំងពីសាលារៀន ការចេញថវិកាជួលគ្រូបង្រៀនម៉ោងបន្ថែមដល់កុមារ ។ កម្មវិធីនេះក៏បានធ្វើការ

ផ្សព្វផ្សាយពីសារសំខាន់ នៃការអប់រំកុមារីដល់សហគមន៍ផងដែរ ដើម្បីផ្លាស់ប្តូរឥរិយាបទរបស់សង្គមអោយបញ្ជូនកូនស្រីទៅរៀនអោយបានច្រើន និងខ្ពង់ខ្ពស់ដើម្បីលើកស្ទួយជីវភាពគ្រួសារអោយកាន់តែប្រសើរឡើង តាមរយៈការបញ្ចាំងភាពយន្តចល័ត និងយុទ្ធនាការនានា ដូចជាយុទ្ធនាការចុះឈ្មោះចូលរៀន យុទ្ធនាការបញ្ឈប់ការជួញដូរស្ត្រី យុទ្ធនាការ១៨ថ្ងៃប្រឆាំងនឹងអំពើហិង្សាលើស្ត្រី យុទ្ធនាការសិទ្ធិនារី វេទិកាថ្នាក់ខេត្ត និងថ្នាក់ជាតិ កម្មវិធីសន្ទនាបន្តផ្ទាល់តាមវិទ្យុ កិច្ចពិភាក្សាតុមូលតាមទូរទស្សន៍ ។ កម្មវិធីនេះដំណើរការទៅដោយជោគជ័យ ដោយសារមានការសហការពីមន្ទីរអប់រំខេត្ត ក្រុមការងារអប់រំថ្នាក់ស្រុក (កិច្ចការនារី និងអប់រំស្រុក) និងក្រុមការងារអប់រំថ្នាក់មូលដ្ឋាន រួមមាន នាយកសាលា នាយកកំរង លោកគ្រូ អ្នកគ្រូ សមាគមមាតាបិតាសិស្ស តំណាងសិស្ស និងក្រុមប្រឹក្សាឃុំ-សង្កាត់ សរុបទាំងអស់ចំនួន ១២៨ នាក់។ ក្រុមការងារនេះមានតួនាទីជ្រើសរើសសិស្សតាមដានការសិក្សារបស់សិស្ស ជួយលើកទឹកចិត្តមាតាបិតា និងសិស្សដែលបោះបង់ការសិក្សា រឺចូលរៀនមិនទៀងទាត់ ចែកកញ្ចប់អាហារូបករណ៍ និងចូលរួមដោះស្រាយបញ្ហារបស់សិស្ស និងជួយរៀបចំយុទ្ធនាការផ្សេង ៗ ក្នុងតំបន់ ។

**<u>៨- ក្លិបយុវជនៈ</u>** អង្គការ CWCC បានបង្កើតអោយមានក្លិបយុវជនស្ម័គ្រចិត្តចំនួន ២០ក្លិប ដែលសរុបមានយុវជនចំនួន ៣០០នាក់ ក្នុងនោះមាន ៦៧ ភាគរយជាកុមារី និងស្ត្រី ដើម្បីអប់រំយុវជនអោយមានបទពិសោធន៍ជំនាញ និងចេះធ្វើការងារសង្គម ។ យុវជនស្ម័គ្រចិត្តក៏បានចូលរួមចំណែកក្នុងការជួយផ្សព្វផ្សាយ ពីច្បាប់នៃអំពើហិង្សាក្នុងគ្រួសារ ការជួញដូរ និងការរំលោភលើស្ត្រី យ៉ាងសកម្ម តាមរយៈការសំដែង ល្ខោន និងកំប្លែង និងយុទ្ធនាការផ្សព្វផ្សាយផ្សេង ៗ ។

**<u>៩-ការតស៊ូមតិៈ</u>** ចូលរួមផ្សព្វផ្សាយច្បាប់ និងរួមចំណែកទាមទារអោយមានការបង្កើតច្បាប់នានា ដើម្បីការពារស្ត្រី និងកុមារ ជាពិសេស ច្បាប់ប្រឆាំងនឹងអំពើហិង្សាក្នុងគ្រួសារ ច្បាបទប់ស្កាត់ការជួញដូរ និងច្បាប់ផ្សេងៗ ទៀតដែលទាក់ទងនឹងស្ត្រី តាមរយៈកិច្ចពិភាក្សាតុមូល វេទិកាសាធារណៈ សិក្ខាសាលាថ្នាក់ជាតិ ការផ្សព្វផ្សាយស្ពតវីដេអូអប់រំតាមទូរទស្សន៍ និង តាមវិទ្យុ យុទ្ធនាការចុះឈ្មោះចូលរៀន ទិវាអក្ខរ កម្មជាតិ ទិវាកុមារអន្តរជាតិ ទិវានារីអន្តរជាតិ ។ល។

ព្រះថេរានុថេរៈគ្រប់ព្រះអង្គ ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតី ជាទីគោរព ថ្មីៗនេះ អង្គការ CWCC បានបង្កើតកម្មវិធីពីរផ្សេងទៀតៈ

**<u>១០- កម្មវិធីគ្រប់គ្រងកំហឹងបុរសៈ</u>** កម្មវិធីនេះមានគោលបំណងផ្តល់ការពិគ្រោះយោបល់ដល់បុរសដែលងាយប្រព្រឹត្តិអំពើហិង្សា និងដល់បុរសដែលបានប្រព្រឹត្តអំពើហិង្សាអំពីវិធីគ្រប់គ្រងកំហឹង និងការទទួលខុសត្រូវផ្នែកច្បាប់ នៅពេលដែលខ្លួនប្រើអំពើហិង្សា រួចចងក្រង និងពង្រឹងសមត្ថភាព បុរសដែលឈប់ប្រើហិង្សា អោយចេះជួយបុរសដែលកំពុងប្រើហិង្សាអោយឈប់ប្រព្រឹត្តអំពើហិង្សា ។

**១១-ឡានផ្សព្វផ្សាយចល័តៈ** ដើម្បីទប់ស្កាត់ការជួញដូរកុមារពលកម្មតាមច្រកទ្វារនានា នៅតាមព្រំដែនដោយផ្តល់ឱកាសអោយកុមារទាំងនេះទទួលបានការសិក្សា អក្ខរកម្ម ការព្យាបាលនិងថែទាំសុខភាព និងព័ត៌មានអំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងគេចផុតពីការជួញដូរមនុស្ស ។ កម្មវិធីនឹងបញ្ជូនកុមាររងគ្រោះដោយពលកម្ម ដើម្បីវិលត្រឡប់ទៅទទួលការអប់រំ ទាំងការបណ្តុះបណ្តាលជំនាញ ឬការអប់រំក្នុងប្រព័ន្ធ តាមរយៈកម្មវិធីអាហារូបករណ៍ ។

ព្រះថេរានុថេរៈគ្រប់ព្រះអង្គ ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិជាទីគោរព!

អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ អាចសំរេចដោយជោគជ័យនូវបណ្តាសមិទ្ធិផលខាងលើនេះបានក៏អាស្រ័យដោយការខិតខំប្រឹងប្រែងក្នុងការជួយឧបត្ថម្ភ និងការសហការយ៉ាងជិតស្និទ្ធពីសំណាក់ ឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងស្ថាប័នមន្ទីរពាក់ព័ន្ធ នគរបាល កងរាជអាវុធហត្ថ កងកំលាំងប្រដាប់អាវុធ និងអាជ្ញាធរមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ នៅខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប និងទីក្រុងភ្នំពេញ និងការលះបង់ទាំងកំលាំងកាយ និងកំលាំងចិត្តពីបុគ្គលិក និងបណ្តាញទាំងអស់ ។

ទន្ទឹមនឹងជោគជ័យទាំងអស់ ដូចដែលបានរៀបរាប់ខាងលើនេះ យើងបានជួបប្រទះនូវឧបសគ្គជាច្រើនដោយសារការងារមនុស្សធម៌របស់យើងបានធ្វើអោយប៉ះពាល់ រឺបាត់បង់ផលប្រយោជន៏របស់បុគ្គលមួយចំនួន និងជនល្មើសទាំងនោះ ។ ឧបសគ្គទាំងនោះរួមមាន ដូចខាងក្រោមៈ

- មេបននិងបក្សពួកធ្លាប់បានយកកាំភ្លើង និងគ្រាប់បែកមកគំរាមកំហែងក្នុងគោលបំណងយកជនរងគ្រោះត្រលប់ទៅផ្ទះបនវិញ

- មានការគំរាម ចាប់រំលោភ និងសំលាប់បុគ្គលិកតាមទូរស័ព្ទ

-គំរាមជះទឹកអាស៊ីត និងបញ្ឆេះ និងបើកគៀរឡានបុគ្គលិកអោយឈប់

-មានជនបិទមុខចាប់ជនរងគ្រោះ និងគំរាមអោយដកពាក្យបណ្តឹង

-ផ្លោះរបងចូលមណ្ឌល និងមកមណ្ឌលដើម្បីរុករកជនរងគ្រោះ

-បង្ខូចកេរ្តិ៍ឈ្មោះអង្គការថា អង្គការបង្កើតរឿងប្រឆាំងពួកគេដើម្បីបានជំនួយ យកលុយសំណង របស់ជនរងគ្រោះ ដែលតុលាការសុំអោយយកមកអោយជនរងគ្រោះ

-ទិញទឹកចិត្តជនរងគ្រោះអោយដកពាក្យបណ្តឹង ដោយចោទថាអង្គការបង្ខំអោយជណរងគ្រោះឆ្លើយចោទប្រកាន់ជនល្មើស

- បង្ខូចកេរ្តិ៍ឈ្មោះអង្គការតាមប្រព័ន្ធអ៊ីនធឺណិត និងវេបសាយ ដោយចោទថា អង្គការចាប់បង្ខាំងក្មេងក្នុងមណ្ឌលអោយទំលាក់កំហុសលើជនល្មើស

- ប្តីជនរងគ្រោះមួយចំនួនបានចោទអង្គការថាបានបំបែកបំបាក់ និងនាំស្ត្រីធ្វើបដិវត្តន៍ប្រឆាំងនឹងពួកគេ ដែលពីមុនមកស្ត្រីរងគ្រោះមិនហ៊ានធ្វើការតវ៉ាអ្វីឡើយ

-ជួលជនរងគ្រោះក្លែងក្លាយអោយប្តឹងអង្គការ និង

-មានបុគ្គលិកម្នាក់ត្រូវបានគេកាប់១៩ពូថៅស្ទើរតែបាត់បង់ជីវិត យើងមានការសង្ស័យថាជារឿងពាក់ព័ន្ធនឹងការជួយស្ត្រី ។

ចំពោះបញ្ហាប្រឈមទាំងនេះ នាងខ្ញុំសូមថ្លែងអំណរគុណ នគរបាល និងកងរាជអាវុធហត្ថដែលតែងតែបានធ្វើអន្តរាគមន៍ពេលមានបញ្ហាកើតឡើងនៅក្នុងមណ្ឌល និងការិយាល័យ ។ សូមថ្លែងអំណរគុណដល់បណ្ដា អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នជាតិ ដែលតែងតែជួយជាកំលាំងចិត្តនៅពេលដែលអង្គការ យើងទទួលរងនូវការវាយប្រហារពីជនល្មើស និងបក្សពួក ។ ជាងនេះទៅទៀតយើងបានទទួលនូវរង្វាន់កិត្តិយសជា**អ្នកដឹកនាំលេចធ្លោ** ដែលជារង្វាន់ខ្ពង់ខ្ពស់បំផុតនៅទ្វីបអាស៊ី ពីលោកស្រីប្រធានាធិបតីហ្វីលីពីន **រង្វាន់កិត្តិយសផ្នែកសិទ្ធិ មនុស្ស** ពីសភាជប៉ុន រង្វាន់ជា**អ្នកដឹកនាំវ័យក្មេង**របស់វេទិកាសេដ្ឋកិច្ចពិភពលោក និងត្រូវបានតែងតាំងជាបេក្ខជនពានរង្វាន់ណូបែលសន្តិភាពពិភពលោកកាលពីឆ្នាំមុន ។ រង្វាន់កិត្តិយសទាំងនេះបានជួយផ្តល់កំលាំងចិត្ត ដល់បុគ្គលិក និង អ្នកស្ម័គ្រចិត្តរបស់យើងយ៉ាងខ្លាំង ទោះបីជាយើងមិនដែលបានគិតថាចង់បានរង្វាន់ រឺតំលៃតបស្នងក៏ដោយ ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំព្រះករុណា នាងខ្ញុំសូមសំដែងនូវអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះអាជ្ញាធរមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ ស្ថាប័នមន្ទីរពាក់ព័ន្ធ ដូចជា ក្រសួងមហាផ្ទៃ ក្រសួងកិច្ចការនារី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នគរបាល កងរាជអាវុធហត្ថ កងកំលាំងប្រដាប់អាវុធ នាយកដ្ឋានប្រឆាំង ការជួញដូរក្រសួងមហាផ្ទៃ ការិយាល័យប្រឆាំងការជួញដូរខេត្ត ក្រុង និងប្រជាពលរដ្ឋទាំងអស់ ដែលបានចូលរួមសហការជួយធ្វើអោយដំណើរការការងារនេះទទួលបានលទ្ធផលជាផ្លែផ្កាគួរជាទីមោទនៈ ។ ជាក់ស្តែង យើងឃើញថាបច្ចុប្បន្ននេះ ស្ថានភាពស្ត្រីកាន់តែមានភាពប្រសើរឡើងជាលំដាប់ និងមានការយកចិត្តទុកដាក់យ៉ាងខ្លាំងពីរដ្ឋាភិបាល និងពីគ្រប់មជ្ឈដ្ឋាន ។ នាងខ្ញុំសង្ឃឹមជឿជាក់ថា ឯកឧត្តម លោកជំទាវ លោក លោកស្រីនឹងបន្តកិច្ចសហការដ៏ល្អនេះតទៅទៀត ជាពិសេសក្នុងការផ្តល់សុវត្ថិភាព ដល់បុគ្គលិក និងជនរងគ្រោះ ដើម្បីរួមគ្នាលុបបំបាត់អំពើហិង្សាគ្រប់ប្រភេទលើស្ត្រី និងកុមារ រួមគ្នាអនុវត្តច្បាប់ ទប់ស្កាត់អំពើហិង្សា និងកិច្ចការពារជនរងគ្រោះអោយមានប្រសិទ្ធភាព និងរួមគ្នាលើកស្ទួយជីវភាព សេចក្តីថ្លៃថ្នូរ និងតម្លៃស្ត្រីនៅក្នុងសង្គម ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្រ និងពង្រឹងតួនាទីស្ត្រីអោយបានជោគជ័យ សមស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា។ អង្គការ CWCC ប្តេជ្ញាបន្តចូលរួមចំណែកជាមួយរដ្ឋាភិបាលក្នុងការលុបបំបាត់អំពើហិង្សាលើស្ត្រីដើម្បីសុភ មង្គល ក្នុងគ្រួសារ និងសង្គម ។

នាងខ្ញុំសូមសំដែងនូវការដឹងគុណ និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅបំផុត ចំពោះម្ចាស់ជំនួយទាំងអស់មានដូចជា អង្គការ Terre Des Hommes of Germany, Terre Des Hommes of Netherlands, ក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍នៃរដ្ឋាភិបាលអាល្លឺម៉ង់ (BMZ) , UNICEF, OXFAM-H.K

និងជំនួយព្រះវិហារដាណឺម៉ាក់ (DCA), Lotus Outreach, Asia Foundation, UNIFEM, Ramon Masaysay, Church World Services, Global Fund For Women, AusAid, USAID, EWMI, Oak Foundation, Ockenden Venture, Operation A Day's Work, GAATW, Canada Fund, IRWAR, Policy Project, Tide Foundation and World Food Program ដែលបានផ្តល់ថវិកាដល់អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ អោយមានលទ្ធភាពធ្វើសកម្មភាពខ្លួនរហូតមកទល់ពេលនេះ ជាពិសេស នាងខ្ញុំសូមសំដែងនូវការគោរពដល់វិញ្ញាណខ័ន្ធ លោកបណ្ឌិត វៃលធី ស្រ្តូបានិក ដែលបានបូជាកម្លាំងកាយចិត្ត និងប្រាជ្ញាស្មារតីពេញមួយជីវិត ដើម្បីបំពេញការងារមនុស្សធម៌ក្នុងការជួយគាំទ្រដល់ស្ត្រី និងកុមារក្រលំបាក រងគ្រោះ គ្មានទីពឹង នៅពាសពេញអាស៊ី ក៏ដូចជានៅកម្ពុជា អោយទទួលបាននូវក្តីសង្ឃឹមក្នុងជីវិតជាថ្មីឡើងវិញ ។

ព្រះថេរានុថេរៈគ្រប់ព្រះអង្គ ជាទីគោរពសក្ការៈ!

ឯកឧត្តម លោកជំទាវ អស់លោក-លោកស្រី អ្នកនាងកញ្ញា ជាទីរាប់អាន !

ជាថ្មីម្តងទៀត តាងនាមអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ ខ្ញុំព្រះករុណា នាងខ្ញុំសូមគោរពថ្លែងអំណរព្រះគុណ និងអំណរគុណ ដ៏ជ្រាលជ្រៅបំផុត ចំពោះព្រះថេរានុថេរៈគ្រប់ព្រះអង្គ ឯកឧត្តម លោកជំទាវ លោកលោកស្រីដែលបានឆ្លៀតពេលដ៏មមាញឹក ផ្តល់កិត្តិយសអញ្ជើញមកចូលរួមក្នុងពិធីសម្ពោធមណ្ឌលសុវត្ថិភាព និងទិវាខួប ១០ឆ្នាំ នៃអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិថ្ងៃនេះ ដែលញ៉ាំងអោយពិធីនេះប្រព្រឹត្តទៅយ៉ាងអធឹកអាធមក្រៃលែង ។

ខ្ញុំព្រះករុណា នាងខ្ញុំសូមគោរពថ្លែងអំណរគុណចំពោះមន្ត្រី បុគ្គលិក អ្នកស្ម័គ្រចិត្តជាតិ និងអ្នកស្ម័គ្រចិត្តអន្តរជាតិ នៃអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិទាំងអស់ ទាំងបីខេត្តក្រុង ដែលបានខិតខំបំពេញកិច្ចការងារជំនះរាល់ឧបសគ្គ និងគ្រោះថ្នាក់ទាំងឡាយ ដើម្បីជំរុញការងារអោយបានជោគជ័យរហូតដល់មានថ្ងៃនេះ ។

ជាទីបញ្ចប់នេះ ខ្ញុំព្រះករុណា នាងខ្ញុំសូមគោរពប្រគេនពរដល់ ព្រះថេរានុថេរៈគ្រប់ព្រះអង្គ និងសូមគោរពជូនពរដល់ ឯកឧត្តមគណៈអធិបតី ឯកឧត្តម លោកជំទាវ លោក- លោកស្រី អ្នកនាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិ សូមជួបប្រទះតែសេចក្តីសុខគ្រប់ប្រការ និងជ័យជំនះគ្រប់ពេលវេលា ហើយសូមជួបតែនឹងពុទ្ធពរទាំងប្រាំប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លាងឃ្លាតឡើយ ។

សូមអរព្រះគុណ និងសូមអរគុណ !